# គម្រោងអភិបាលកិច្ចល្អ មូលដ្ឋាន

ខែ មេសា ឆ្នាំ ២០០៩

# ការចាប់ផ្តើមអនុវត្តគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន

*ធនាគារពិភពលោកកំពុងផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងទឹកប្រាក់ចំនួន ២០ លានដុល្លារអាមេរិក តាមរយៈសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) សម្រាប់គម្រោងថ្មីមួយដែលមានទឹកប្រាក់ចំនួន ២៥.៥ លានដុល្លារអាមេរិក ពោលគឺគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន (DFGG) ។ ឯកឧត្តម ងី ចន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ គឺជាប្រធានសម្របសម្រួលគម្រោង។ ឯកឧត្តម បានពន្យល់អំពីអ្វីដែលគម្រោងសំដៅសម្រេចឱ្យបាន និងអត្ថប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា។*



*ឯកឧត្តម ងី ចន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានសម្របសម្រួលគំរោងអភិបាលកិច្ចល្អមូលដ្ឋាន។*

***សូមឯកឧត្តមមេត្តាប្រាប់យើងខ្ញុំអំពីគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន និងអំពីអត្ថន័យនៃគម្រោងនេះសម្រាប់កម្ពុជា?***

គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន គឺសំដៅលើកម្រិតនិងលទ្ធភាពរបស់ប្រជាពលរដ្ឋ និងតួអង្គមិនមែនរដ្ឋផ្សេងៗទៀត ក្នុងការលើកស្ទួយ "សម្លេង" របស់ខ្លួន និងទាមទារឱ្យរដ្ឋមានគណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់សារៈសំខាន់នៃការពង្រឹងអភិបាលកិច្ចនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦ - ២០១០ របស់ខ្លួន ហើយក៏ជាស្នូលសម្រាប់យុទ្ធសាស្ត្រចតុកោណដែរ។ យុទ្ធសាស្ត្រនេះបានកំណត់វិស័យគន្លឹះនានាសម្រាប់កំណែទម្រង់អភិបាលកិច្ច រួមមានប្រព័ន្ធច្បាប់ និងតុលាការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ និងវិមជ្ឈការ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ជាសាធារណៈផងដែរថា "ការសម្រេចបានអភិបាលកិច្ចល្អ នឹងតម្រូវឱ្យមានការចូលរួមដ៏សកម្មនិងការប្តេជ្ញារបស់មជ្ឈដ្ឋានសង្គមទាំងអស់ ការចែករំលែកព័ត៌មានកាន់តែប្រសើរឡើងគណនេយ្យភាព តម្លាភាព សមធម៌ ការរាប់បញ្ចូលឱ្យបានពេញលេញ និងវិធាននៃច្បាប់"។

និយាយឱ្យខ្លី អភិបាលកិច្ចគឺជានីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត និងកិច្ចដំណើរការ ដែលនៅក្នុងនោះ សេចក្តីសម្រេចចិត្តនានាត្រូវបានអនុវត្ត។ អភិបាលកិច្ចល្អត្រូវការការចូលរួមយ៉ាងទូលាយ ការចែករំលែកព័ត៌មាន ការបើកចំហនិងតម្លាភាព គណនេយ្យភាព ភាពឆ្លើយតប ប្រសិទ្ធិភាពនិងភាពស័ក្តិសិទ្ធិ សមធម៌ ការរាប់បញ្ចូលឱ្យបានពេញលេញ និងវិធាននៃច្បាប់

ដ៏តឹងរ៉ឹង។ វាធានាឱ្យបានថាអំពើពុករលួយ ត្រូវបានកាត់បន្ថយ ទស្សនៈរបស់មតិភាគតិចត្រូវបានពិចារណា និងថាសម្លេងរបស់ជនងាយរងគ្រោះបំផុតក្នុងសង្គមត្រូវបានគេស្តាប់ឮនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ វាក៏ឆ្លើយតបផងដែរទៅនឹងសេចក្តីត្រូវការបច្ចុប្បន្ន និងអនាគតរបស់សង្គម។

## *តើគម្រោងតម្រូវការអភិបាលកិច្ចល្អមូលដ្ឋានមានសារៈសំខាន់យ៉ាងដូចម្តេចចំពោះប្រទេសកម្ពុជា?*

អភិបាលកិច្ចល្អ គឺជាបុព្វលក្ខខណ្ឌសំខាន់បំផុតសម្រាប់សម្រេចបាននូវកិច្ចអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ជាមួយនឹងសមធម៌ ឱកាសស្មើភាពគ្នា និងយុត្តិធម៌សង្គម។ គម្រោងតម្រូវការអភិបាលកិច្ចល្អនេះ គឺជាការឆ្លើយតបទៅនឹងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់កំណែទម្រង់។ ទស្សនាទានគម្រោងមានសង្គតិភាពជាមួយ នឹងអាទិភាពដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បី "កំណើនការងារ សមធម៌ និងប្រសិទ្ធភាព"។

គម្រោងនេះ នឹងបំពេញបន្ថែមលើការផ្តត់ផ្គង់ជាមួយ នឹងអភិក្រមតម្រូវការអភិបាលកិច្ចល្អ ដែលត្រូវបានពង្រឹងជាបន្តបន្ទាប់តាមរយៈកំណែទម្រង់នៅក្នុងវិស័យគន្លឹះនានា។ គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អអភិបាលកិច្ចបានផ្តោតលើការផ្តត់ផ្គង់ ពោលគឺ ការពង្រឹងសេវាកម្មពលរដ្ឋរដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កិច្ចប្រឹងប្រែងផ្តត់ផ្គង់ទាំងនេះ គឺសំខាន់និងចាំបាច់ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានសម្តែងឆន្ទៈមុះមុតក្នុងការអនុវត្តឱ្យបានហួសពីអភិក្រមផ្គង់ផ្គង់ដើម្បីកែលម្អអភិបាលកិច្ចល្អ ហើយដោយសារមូលហេតុនេះហើយដែលគម្រោងតម្រូវការអភិបាលកិច្ចល្អមូលដ្ឋានគឺសំខាន់ ហើយវានឹងបំពេញបន្ថែមលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះរបៀបវារៈកំណែទម្រង់ធំៗ។ គម្រោងការអភិបាលកិច្ចល្អមូលដ្ឋាន នឹងផ្តល់កាលានុវត្តភាពដើម្បីពង្រឹងសមត្ថភាពរបស់ស្ថាប័នរដ្ឋនិងស្ថាប័នមិនមែនរដ្ឋ និងភាពជាដៃគូនៅក្នុងតម្រូវការអភិបាលកិច្ច។

## *រាជរដ្ឋាភិបាលបានប្រកាសគោលនយោបាយ មួយនៃទិដ្ឋភាពធ្វើវិសហមជ្ឈការរដ្ឋានរដ្ឋបាលរបស់ខ្លួន។ តើគម្រោងអភិបាលកិច្ចល្អមូលដ្ឋានមានតួនាទីអ្វីនៅក្នុងគោលនយោបាយនេះ?*

ដោយមានការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (ថ្នាក់ក្រោមជាតិ) និង ទោះបីជា មានផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្នក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុះមុត និងបាន ចាប់ផ្តើមអនុវត្តរបៀបវារៈកំណែទម្រង់ដ៏ធំមួយ ដោយផ្តោតជាក់ស្តែងលើកិច្ចអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិជាបន្តបន្ទាប់។ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៩ ការបោះឆ្នោតនឹងត្រូវបានរៀបចំនៅក្នុងទូទាំងប្រទេសដើម្បីជ្រើសរើសក្រុមប្រឹក្សាដែលគ្រប់គ្រងនិងបំពេញមុខងារថ្មីចំនួន ២២៥ នៅកម្រិតរដ្ឋបាលផ្សេងៗ ដែលជាយថាហេតុនឹងកែប្រែបន្តិចម្តងៗនូវរបៀបដែលនៅក្នុងនោះអភិបាលកិច្ចនិងកិច្ចអភិវឌ្ឍត្រូវបានរៀបចំជាផែនការគ្រប់គ្រងនិងទទួលខុសត្រូវនៅថ្នាក់ក្រោមជាតិ។

កិច្ចដំណើរការនៃការធ្វើប្រតិបត្តិការទស្សនាទានគម្រោងអភិបាលកិច្ចល្អមូលដ្ឋាននេះ ត្រូវបានសម្រេចតាមរយៈសកម្មភាពគន្លឹះ ចំនួនបួនៈ

- ជម្រុញតម្រូវការដោយការបញ្ចេញ ការបំភ្លឺ និងការផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីសំខាន់ៗរបស់រាជរដ្ឋាភិបាល
- សម្រួលតម្រូវការដោយបង្កើតនិងពង្រឹងច្រកសម្រាប់ការផ្តល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋ និងការដោះស្រាយការបារម្ភរបស់ប្រជាពលរដ្ឋ
- ឆ្លើយតបទៅនឹងតម្រូវការដោយបង្កើតកម្មវិធីនានាដើម្បីផ្តល់សេវាកម្ម និង
- ជម្រុញឱ្យមានការឃ្លាំមើលនិងការត្រួតពិនិត្យទៀងទាត់លើវិស័យសាធារណៈដោយស្ថាប័នឯករាជ្យ។

នៅក្នុងកិច្ចដំណើរការនេះ យើងកំពុងស្ថាបនានិងពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចល្អដើម្បីឱ្យប្រទេសកម្ពុជាលើកស្ទួយប្រសិទ្ធភាព នៅក្នុងការអនុវត្តន៍គោលនយោបាយ និងការផ្តល់និងការគ្រប់គ្រងទំនិញសាធារណៈ ជាពិសេស ការផ្តល់សេវាកម្មកាន់តែប្រសើរឡើងដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា។

### *តើសកម្មភាពអ្វីខ្លះនឹងត្រូវបានគាំទ្រនៅក្នុងគម្រោងនេះ? តើមានស្ថាប័នអនុវត្តប៉ុន្មានចូលរួម និងតើស្ថាប័នទាំងនេះ នឹងផ្តោតលើអ្វីខ្លះ?*

គម្រោងនេះ មានសមាសភាគបី: ការគាំទ្រចំពោះស្ថាប័នរដ្ឋ ការគាំទ្រចំពោះស្ថាប័នមិនមែនរដ្ឋ និងការសម្របសម្រួលនិងការរៀនសូត្រ ។

**សមាសភាគទីមួយ**នៃគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន នឹងគាំទ្រស្ថាប័នរដ្ឋចំនួនបួន ពោលគឺ:

- ក្រុមប្រឹក្សាអាជ្ញាកណ្តាល (AC) - ដែលរួមចំណែកដល់ការកសាងបរិស្ថានអភិបាលកិច្ចប្រកបដោយប្រសិទ្ធិភាពមួយសម្រាប់កិច្ចអភិវឌ្ឍន៍ផ្នែកឯកជន ដោយដោះស្រាយវិវាទការងារ សមូហភាពរវាងនិយោជកនិងនិយោជិត
- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដែលទទួលខុសត្រូវលើការផ្សព្វផ្សាយច្បាប់ និងចាត់ចែងលើពាក្យបណ្តឹង
- ការិយាល័យច្រកចេញ-ចូលតែមួយ (OWSO) និងការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក (District Ombudsman) ដែលផ្តល់សេវាកម្មរដ្ឋបាល ចាំបាច់នានាជូនប្រជាពលរដ្ឋ និងអាជីវកម្មតូចតាច នៅក្រោមដំបូលតែមួយ និងបង្កើតច្រកមួយសម្រាប់ ទូលពាក្យបណ្តឹងពីប្រជាពលរដ្ឋនិងសហគមន៍អាជីវកម្ម អំពីការងារប្រតិបត្តិរបស់មន្ត្រីថ្នាក់ស្រុក និង
- វិទ្យុជាតិកម្ពុជា ដែលនឹងបំពេញចន្លោះប្រហោងមួយនៅក្នុងការមានជាសាធារណៈនូវកម្មវិធីវិទ្យុប្រកបដោយតុល្យភាពត្រឹមត្រូវ និងទាន់សភាពការណ៍ ដែលជូនព័ត៌មាន និងជួយសម្រួលការជជែកពិភាក្សារវាងប្រជាពលរដ្ឋស្ថាប័នមិនមែនរដ្ឋ អាជីវកម្ម និងរាជរដ្ឋាភិបាល លើប្រធានបទដែលជាផលប្រយោជន៍សាធារណៈ ។

**សមាសភាគទីពីរ**នៃគម្រោងត្រូវបានគ្រោងដើម្បីផ្តល់ជំនួយឥតសំណងនិងជំនួយកសាងសមត្ថភាព ជូនដល់ស្ថានប័នមិនមែនរដ្ឋដើម្បីពង្រឹងការងារទាក់ទិននឹងអភិបាលកិច្ចរបស់ពួកគេ ។ ដើម្បីធានាឱ្យបាននូវឯករាជ្យភាពរបស់តួអង្គមិនមែនរដ្ឋ រាជរដ្ឋាភិបាល បានឯកភាពថាសមាសភាគ នេះនឹងត្រូវបានអនុវត្ត



*ឯកឧត្តម ងី ចន្ទ្រផល ពិនិត្យមើលតារាងតំលៃសេវាកម្មនៅការិយាល័យច្រកចេញចូលតែមួយនៅស្រុកបាត់ដំបង ។*

ដោយមូលនិធិអាស៊ី (The Asia Foundation) ដែលគឺជាស្ថាប័នមិនមែនរដ្ឋមួយដែលមានសមត្ថភាព បទពិសោធន៍ និងវត្តមានគ្រប់គ្រាន់នៅប្រទេសកម្ពុជា ។

សមាសភាគនេះ នឹងផ្តល់មូលនិធិបន្តដល់ស្ថាប័នមិនមែនរដ្ឋផ្សេងៗ (ដូចជាអង្គការមិនមែនរដ្ឋាភិបាលជាតិក្នុងស្រុក អង្គការថ្នាក់មូលដ្ឋានផ្សេងទៀត មជ្ឈមណ្ឌលគោលនយោបាយ និងស្រាវជ្រាវ ឯករាជ្យ សារព័ត៌មានឯករាជ្យ សមាគមអាជីព សមាគមអាជីវកម្ម និងសហជីព) ដើម្បីជួយគាំទ្រដល់សំណើរបស់ពួកគេក្នុងការបង្កើនសកម្មភាពកំពុងដំណើរការឬសាកល្បងសកម្មភាពថ្មីៗ ដែលពង្រឹងតម្រូវការអភិបាលកិច្ចល្អ និងរួមចំណែកដល់កិច្ចអភិវឌ្ឍឬគោលដៅវិស័យជាក់លាក់នានា ។ ស្ថាប័នមិនមែនរដ្ឋ ទាំងអស់ដែលទទួលជំនួយឥតសំណង នឹងត្រូវបានតម្រូវឱ្យគោរព តាមគោលការណ៍*ចូលរួមក្នុងលក្ខណៈស្ថាបនា*មួយចំនួនដែលកំពុងត្រូវបានរៀបចំ ដោយមានការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលនិងស្ថាប័នមិនមែនរដ្ឋ ។

### *តើហិរញ្ញប្បទានឥតសំណងនឹងត្រូវបានផ្តល់យ៉ាងដូចម្តេច នឹងផ្តល់ជូនអ្នកណា?*

ហិរញ្ញប្បទានឥតសំណងនឹងរួមមានពីរប្រភេទ: *ហិរញ្ញប្បទានឥតសំណងភាពជាដៃគូ* និង *ហិរញ្ញប្បទានឥតសំណងតាមប្រធានបទ* ។

***ហិរញ្ញប្បទានឥតសំណងភាពជាដៃគូ*** - ប្រហែល ២៥ ភាគរយនៃមូលនិធិហិរញ្ញប្បទានឥតសំណងដែលត្រូវបានវិភាជន៍ឱ្យសមាសភាគនេះ នឹងត្រូវបានផ្តល់ជូនដល់សកម្មភាព

ទាំងឡាយដែលត្រូវបានរៀបចំ និងស្នើឡើងដោយស្ថាប័នមិនមែនរដ្ឋ ប៉ុន្តែត្រូវអនុវត្តក្នុងភាពជាដៃគូជាមួយស្ថាប័នរដ្ឋមួយ ឬច្រើន ដែលគឺជាគោលដៅនៅក្នុងសមាសភាគទី ១។ ហិរញ្ញប្បទានឥតសំណងទាំងនេះ មានបំណងជម្រុញវិធី និងមធ្យោបាយនានាសម្រាប់ឱ្យស្ថាប័នរដ្ឋទាំងបួន និងស្ថាប័នមិនមែនរដ្ឋសហការគ្នាដើម្បីពង្រីកឥទ្ធិពល វិសាលភាព និងប្រសិទ្ធិភាពនៃកម្មវិធីរបស់ខ្លួន រួមមានការឃ្លាំមើលនិងការវាយតម្លៃឯករាជ្យលើសកម្មភាពរបស់ស្ថាប័នរដ្ឋ។ ឧទាហរណ៍ តាមរយៈជំនួយឥតសំណងភាពជាដៃគូ អង្គការសង្គមស៊ីវិលអាចទទួលរៀបចំឱ្យសហគមន៍ឬក្រុមសង្គមជាក់លាក់ណាមួយឆ្លើយតបទៅនឹងឱកាសផ្តល់យោបល់ត្រឡប់ដែលត្រូវបានផ្តល់ជូនដោយវិទ្យុជាតិកម្ពុជា ឬសាកល្បងយន្តការផ្តល់យោបល់ត្រឡប់ថ្មីមួយដែលនឹងលើកស្ទួយប្រសិទ្ធិភាពនៃស្ថាប័នស៊ើបអង្កេតពាក្យបណ្តឹងពលរដ្ឋថ្នាក់ស្រុក នៅក្នុងការិយាល័យច្រកចេញ-ចូលតែមួយ (OWSO)។

*ហិរញ្ញប្បទានឥតសំណងតាមប្រធានបទ* - មូលនិធិភាគច្រើន (ប្រហែល ៧៥ ភាគរយ) នឹងត្រូវបានផ្តល់ជូនដល់ការគាំទ្រចំពោះ គំនិតផ្តួចផ្តើមគម្រោងអភិបាលកិច្ចល្អមូលដ្ឋានដែលដឹកនាំដោយស្ថាប័នមិនមែនរដ្ឋ នៅក្នុងវិស័យកំណែទម្រង់ជាអាទិភាពទាំងបួន ដែលនឹងមានឯករាជ្យភាពពីសកម្មភាពរបស់ស្ថាប័នរដ្ឋទាំងបួន ដែលត្រូវបានផ្តល់មូលនិធិក្រោមសមាសភាគទី ១។ ហិរញ្ញប្បទានឥតសំណងតាមប្រធានបទនឹងជួយសម្រួលការបញ្ជោបគម្រោង អភិបាលកិច្ចល្អមូលដ្ឋាននៅក្នុងវិស័យគន្លឹះទាំងឡាយ ដែលនៅក្នុងនោះ បញ្ហាអភិបាលកិច្ចកំពុងរារាំងដល់ការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា។ ហិរញ្ញប្បទានឥតសំណងតាមប្រធានបទទាំងនេះ គឺសំដៅលើកស្ទួយការរួមចំណែករបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច ការជម្រុញឱ្យមានគំនិតច្នៃប្រឌិត នៅក្នុងគណនេយ្យភាពសង្គម ការពង្រឹងការកសាងបណ្តាញការស្ថាបនាសម្ព័ន្ធភាព និងការជជែកពិភាក្សាជាមួយស្ថាប័នរដ្ឋ និងការកែលម្អបរិស្ថានអំណោយផលសម្រាប់តម្រូវការអភិបាលកិច្ចល្អ។ ឧទាហរណ៍ សកម្មភាពនានា ដែលត្រូវបានគាំទ្រដោយហិរញ្ញប្បទានឥតសំណងតាមប្រធានបទ អាចរួមមានការឃ្លាំមើលនិស្សារណកម្មធនធានធម្មជាតិ ឬ លំហូរប្រាក់ចំណូលនៅតាមខេត្តមួយចំនួន ដោយបណ្តាញមួយនៃអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអង្គការថ្នាក់មូលដ្ឋាន ដែលត្រូវបានគាំទ្រដោយមជ្ឈមណ្ឌលស្រាវជ្រាវឯករាជ្យមួយ ឬការធ្វើយុទ្ធនាការនិងការរួមចំណែកដល់ការរៀបចំក្របខ័ណ្ឌសេរីភាពព័ត៌មានដោយសម្ព័ន្ធភាពមួយនៃក្រុម សារព័ត៌មានឯករាជ្យ។

## *តើមានអ្វីខ្លះនៅក្នុងសមាសភាគទីបីៈ ការសម្របសម្រួល និងការរៀនសូត្រ?*

**សមាសភាគទីបី** នឹងគាំទ្រការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធិភាពជារួម តាមរយៈការសម្របសម្រួលនិងការរៀនសូត្រ។ ដោយសារស្ថាប័នប្រតិបត្តិនៃគម្រោង ពោលគឺក្រសួងមហាផ្ទៃ នឹងបំពេញតួនាទីសម្របសម្រួលមួយ ដោយសហការយ៉ាងជិតស្និតជាមួយស្ថាប័នអនុវត្ត ដើម្បីធានាឱ្យបានថាគោលដៅអភិវឌ្ឍន៍រួមរបស់គម្រោងត្រូវបានសម្រេច។ ក្នុងន័យនេះ ស្ថាប័នប្រតិបត្តិនឹងបង្កើតការិយាល័យសម្របសម្រួលគម្រោង (PCO) *ក្រុមអន្តរស្ថាប័នគ្រប់គ្រងគម្រោង* (PMT) និង *ក្រុមសម្របសម្រួលគម្រោង* (PCG) ដែលនឹងជួយគាំទ្រការអនុវត្តគម្រោងនៅក្នុងវិស័យគ្រប់គ្រងសំខាន់ៗ។ ក្រសួងមហាផ្ទៃ នឹងគ្រប់គ្រងវដ្តផែនការការងារប្រចាំឆ្នាំ ដោយសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីការងារនិងថវិកា។ ក្រសួងមហាផ្ទៃ នឹងបំពេញមុខងារជាលេខាធិការដ្ឋាននៃក្រុមសម្របសម្រួលគម្រោង ដោយជម្រុញឱ្យមានការចែករំលែកព័ត៌មានគ្នានៅតាមស្ថាប័នអនុវត្តទាំងឡាយ និង ដោះស្រាយបញ្ហាអនុវត្តនៅពេលដែលវាកើតឡើង។ ក្រសួងមហាផ្ទៃ នឹងធានាឱ្យបាននូវការគ្រប់គ្រងថវិកាគម្រោងឱ្យបានល្អ (សវនកម្ម លទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ) កិច្ចការពារ (បរិស្ថាន និងសង្គម) និងបញ្ហាអភិបាលកិច្ច (ការប្រឆាំងនឹងអំពើពុករលួយ និងការគ្រប់គ្រងហានិភ័យ) ការផ្តល់ជំនួយកសាងសមត្ថភាពជូនស្ថាប័នអនុវត្តនៅក្នុងវិស័យទាំងឡាយដែលជាផលប្រយោជន៍រួម។ ក្រសួងមហាផ្ទៃនឹងបំពេញមុខងារជាចំណុចទំនាក់ទំនងចម្បងជាមួយធនាគារពិភពលោកផងដែរ ដោយជួយសម្រួលការត្រួតពិនិត្យគម្រោងផ្តល់របាយការណ៍វឌ្ឍនភាពទៀងទាត់ និងរៀបចំកាពិនិត្យវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តគម្រោង (ARPI)។ ម្យ៉ាងទៀត ជាផ្នែកមួយនៃតួនាទីសម្របសម្រួលរបស់ខ្លួន ក្រសួងមហាផ្ទៃ ក៏នឹងទទួលភារកិច្ចក្នុងការធានាឱ្យបានផងដែរនូវកិច្ចសហការនិងសុខុមនីយកម្មជាមួយកម្មវិធីស្ថាប័នផ្តល់ជំនួយពាក់ព័ន្ធផ្សេងទៀត តាមរយៈយន្តការនានា ដូចជា ការពិនិត្យវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តគម្រោង (ARPI) វេទិកាអភិបាលកិច្ច

ល្អប្រចាំឆ្នាំ និងកិច្ចជួបប្រជុំនិងការវាយតម្លៃទៀងទាត់ជាដើម ។

*តើទិដ្ឋភាពរៀនសូត្រនៃសមាសភាគនេះមានលក្ខណៈដូចម្តេចដែរ?*

ក្រៅពីការធានាឱ្យបាននូវការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធិភាព សមាសភាគនេះនឹងគាំទ្រកិច្ចដំណើរការដែលមានលក្ខណៈទូលាយ ជាបណ្តើរៗ និង រយៈពេលវែងជាចាំបាច់នៃកំណែទម្រង់អភិបាលកិច្ចនៅប្រទេសកម្ពុជា ដោយលើកកម្ពស់ការយល់ដឹងអំពីការកសាងសមត្ថភាពនៅក្នុងការរៀបចំនិងអនុវត្តសកម្មភាពនានានៃគម្រោងតម្រូវការអភិបាលកិច្ចល្អនៅតាមស្ថាប័ននានានិងហួសពីស្ថាប័នទាំងនេះ ដែលត្រូវបានគាំទ្រដោយផ្ទាល់ដោយសមាសភាគទី ១ និង ២ ។ ដោយប្រកាន់យកជំហរពិភាក្សាសកម្មមុនជាមួយស្ថាប័នអនុវត្ត និងការបង្កើត *ក្រុមគោលដៅរៀនសូត្រនិងទំនាក់ទំនង (LCFG)* មួយដែល នឹងកំណត់កាលានុវត្តភាពសម្រាប់កិច្ចសហប្រតិបត្តិការគ្នា សមាសភាគនេះនឹងជម្រុញឱ្យមានការផ្លាស់ប្តូរទស្សនៈគ្នា និងកិច្ចសហការគ្នានៅតាមបណ្តាស្ថាប័នអនុវត្ត ។ តាមរយៈ *កម្មវិធីលើកកម្ពស់ការយល់ដឹងនិងកសាងសមត្ថភាព* មួយ សមាសភាគនេះនឹងជម្រុញឱ្យមានការរៀនសូត្រអំពីនិងការអនុម័តអភិក្រមនិងការអនុវត្តតម្រូវការអភិបាលកិច្ចល្អ ដោយគាំទ្រវេទិកាអភិបាលកិច្ចល្អប្រចាំឆ្នាំមួយវគ្គសិក្សា និងសិក្ខាសាលាដែលមានគោលដៅច្បាស់លាស់ និងដំណើរទស្សនកិច្ចសិក្សា ។ តាមរយៈ *កម្មវិធីទំនាក់ទំនង* សមាសភាគរងនេះ នឹងជួយបង្កើនការយល់ដឹងនិងភាពលេចធ្លោនៃគម្រោង ជម្រុញឱ្យមានចំណាប់អារម្មណ៍និងការគាំទ្រចំពោះកម្មវិធីរបស់វាតាមដានមើល ការយល់ឃើញអំពីផលប៉ះពាល់នៃកម្មវិធី និងផ្សព្វផ្សាយព័ត៌មានអំពីគំនិតផ្តួចផ្តើមស្រដៀងគ្នា ។ ក្នុងរយៈពេល ខ្លី (នៅក្នុងអំឡុងពេលអនុវត្តគម្រោង) សមាសភាគនេះត្រូវបានរំពឹងថានឹងលើកទឹកចិត្តនិងចាប់ផ្តើមកសាងសមត្ថភាពជូនក្រុមស្ថាប័នរដ្ឋទូលាយជាងមួយដើម្បីឱ្យពួកគេអាចផ្តល់ព័ត៌មាន និងឆ្លើយតបក្នុងរយៈពេលមធ្យមដល់រយៈពេលវែងទៅនឹងតម្រូវការ ការបារម្ភ និងទុក្ខលំបាករបស់ប្រជាពលរដ្ឋ ។

*តើរាជរដ្ឋាភិបាលមានគោលដៅអ្វីខ្លះ ហើយ តើគម្រោងអភិបាលកិច្ចល្អមូលដ្ឋានបំពេញតួនាទីអ្វីខ្លះនៅក្នុងការសម្រេចបានគោលដៅនេះ?*

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំដៅសម្រេចឱ្យបាននូវប្រទេសកម្ពុជាមួយដែលមានឯកភាពសង្គម ការអប់រំជឿនលឿន និងវប្បធម៌រស់រវើក គ្មានភាពក្រីក្រ អនក្ខរកម្ម និងសុខភាពអន់ខ្សោយ ដែលនៅក្នុងនោះប្រជាជនកម្ពុជាទាំងអស់រស់នៅក្នុងសុខុដុមរមណី ចាកផុតពីភាពអត់ឃ្លាន វិសមធម៌ បដិសេធ និងភាពងាយរងគ្រោះ ដែលនៅក្នុងនោះប្រជាពលរដ្ឋទាំងអស់អាចឈានដល់សក្តានុពលដ៏ពេញលេញរបស់ខ្លួននៅក្នុងវិជ្ជាជីវៈជម្រើសរបស់ខ្លួន ដើម្បីរួមចំណែកដល់វឌ្ឍនភាពបន្ថែមទៀតរបស់ប្រទេសជាតិ និងដើម្បីកម្រិតជីវភាពកាន់តែខ្ពស់ឡើង ។

តាមរយៈកិច្ចដំណើរការនៃការពង្រឹងសមត្ថភាពរបស់ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ និងភាពជាដៃគូ ប្រជាពលរដ្ឋកម្ពុជា នឹងទទួលអត្ថប្រយោជន៍តាមរយៈការចូលរួមនិងការខិតខំដ៏សកម្មរបស់គ្រប់មជ្ឈដ្ឋានសង្គមទាំងអស់ការចែករំលែកព័ត៌មានគ្នាកាន់តែប្រសើរឡើងគណនេយ្យភាព តម្លាភាពសមធម៌ការរាប់បញ្ចូលឱ្យបានពេញលេញ និងវិធាននៃច្បាប់ ។ សមត្ថភាពនៅតាមមូលដ្ឋាននឹងត្រូវបានអភិវឌ្ឍ និងកសាងបានច្រើនតាមរយៈការបណ្តុះបណ្តាលនិងការសិក្សាដោយអនុវត្តផ្ទាល់ និងបានបង្កើនយ៉ាង មានប្រសិទ្ធិភាពនូវតម្រូវការឆ្ពោះទៅថ្នាក់លើនូវទំនាក់ទំនងអន្តររដ្ឋាភិបាល និងការផ្តល់សេវាកម្មកាន់តែប្រសើរឡើង ។

គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន មុខជាផ្តល់ឱកាសដើម្បីពង្រឹងសមត្ថភាពរបស់ស្ថាប័នរដ្ឋនិងស្ថាប័នមិនមែនរដ្ឋ និងភាពជាដៃគូ នៅក្នុងតម្រូវការអភិបាលកិច្ចដើម្បីលើកស្ទួយប្រសិទ្ធិភាពក្នុងការអនុវត្តន៍គោលនយោបាយ និងការផ្តល់និងការគ្រប់គ្រងទំនិញសាធារណៈ ជាពិសេស ការផ្តល់សេវាកម្មសាធារណៈកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ។

តាមរយៈគម្រោងនេះ ប្រជាពលរដ្ឋកម្ពុជានឹងទទួលបានព័ត៌មានកាន់តែប្រសើរឡើង ហើយលទ្ធភាពរបស់ពួកគេក្នុងការតម្រូវឱ្យរដ្ឋមានគណនេយ្យភាព ដោយធ្វើឱ្យរដ្ឋឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ខ្លួន នឹងត្រូវបានកែលម្អ ។ ជាលទ្ធផល គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន លើកស្ទួយសមត្ថភាពរបស់រដ្ឋឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និង ឆ្លើយតបទៅកាន់ប្រជាពលរដ្ឋ ។




*ឯកឧត្តម ងី ចន្រ្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ធ្វើបទបង្ហាញអំពីគំរោងអភិបាលកិច្ចល្អមូលដ្ឋានជូនដល់សិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាលការទទួលខុសត្រូវសង្គម ដែលរៀបចំឡើងនាពេលកន្លងមក។*

***តើអ្នកណាផ្តល់ហិរញ្ញប្បទានឱ្យគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន?***

គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន ជាគម្រោងមួយដែលមានទឹកប្រាក់ ២៥,២ លានដុល្លារ សម្រាប់រយៈពេលបួនឆ្នាំ (២០០៩-២០១៣) ដែលសំដៅជម្រុញតម្រូវការអភិបាលកិច្ចល្អនៅក្នុងវិស័យកំណែទម្រង់ជាអាទិភាពនានា ដោយពង្រឹងស្ថាប័នគាំទ្រ ភាពជាដៃគូ និងចែករំលែកមេរៀនគ្នា។ គម្រោងអភិបាល-កិច្ចល្អមូលដ្ឋាន បានទទួលហិរញ្ញប្បទានពី:

- ហិរញ្ញប្បទានឥតសំណង IDA = ២០.០០លានដុល្លារ អាមេរិក
- បដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា=១.៤០ លានដុល្លារ អាមេរិក
- AusAID=៣.៦ លានដុល្លារអាមេរិក និង
- អ្នកផ្តល់ជំនួយផ្សេងទៀត = ០.២ លានដុល្លារ អាមេរិក

***គម្រោងអភិបាលកិច្ចល្អមូលដ្ឋានគឺមានគោលដៅ ច្រើន ហើយតើការតាមដានគម្រោងនេះ ប្រឈមនឹងការលំបាកយ៉ាងណាដែរ?***

ការរៀបចំគម្រោងនេះ គឺជាការលំបាកដ៏ធំមួយសម្រាប់យើង ដោយសារវាថ្មីចំពោះមនុស្សគ្រប់គ្នា ទាំងធនាគារពិភពលោក និងទាំងក្រុមរៀបចំ ប៉ុន្តែវាកាន់តែលំបាកថែមទៀតសម្រាប់យើងនៅក្រសួងមហាផ្ទៃជាស្ថាប័នប្រតិបត្តិក្នុងការតាមដានវឌ្ឍនភាព និងការអនុវត្តគម្រោងអភិបាលកិច្ចល្អមូលដ្ឋាននេះ។ គម្រោងនេះពាក់ព័ន្ធជាមួយស្ថាប័នអនុវត្តជាច្រើន ទាំងស្ថាប័នរដ្ឋផង និងទាំងស្ថាប័នមិនមែនរដ្ឋផង ហើយស្ថាប័នទាំងនេះចូលរួមក្នុងសកម្មភាពខុសៗគ្នា។ គម្រោងអភិបាលកិច្ចល្អមូលដ្ឋានមិនមែនគឺជាគម្រោងមួយដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាក់ស្តែងទេ។ ផ្ទុយទៅវិញ គោលដៅអភិវឌ្ឍន៏គម្រោងនេះ គឺសំដៅជម្រុញតម្រូវការអភិបាលកិច្ចល្អ នៅក្នុងវិស័យកំណែទម្រង់ជាអាទិភាពនានា ដោយពង្រឹងស្ថាប័ន គាំទ្រភាពជាដៃគូ និងចែករំលែកមេរៀនគ្នា។ ហេតុដូច្នេះ គម្រោងនេះមានលក្ខណៈមិនជាក់ស្តែង ប៉ុន្តែសំខាន់ ក្រៃលែង ហើយវាគឺជាកត្តាជម្រុញឱ្យមានការលើកស្ទួយអភិបាលកិច្ចល្អ។

*ព័ត៌មានបន្ថែម សូមទាក់ទង*
*លោក **ម៉ុត ជិក***
*នាយកគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន*
***Email: chik.dfgg@gmail.com***